# ដៃរបស់យើងគឺជាព្រះហស្តរបស់ទ្រង់

*ប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ*
*ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានទីមួយ*

អំឡុងពេលនៃការទម្លាក់គ្រាប់បែកទៅលើទីក្រុងមួយក្នុងសង្គ្រាមលោកលើកទីពីរ មានដំណើររឿងមួយត្រូវបានគេនិទានថា រូបសំណាកដ៏ធំរបស់ព្រះយេស៊ូវបានទទួលការខូចខាតយ៉ាងខ្លាំង។ នៅពេលប្រជាពលរដ្ឋបានរកឃើញរូបសំណាកនោះនៅលាយជាមួយនឹងកំទេចថ្ម ពួកគេបានទួញសោកពីព្រោះវាគឺជានិមិត្តរូបនៃសេចក្តីជឿ និងវត្តមានរបស់ព្រះនៅក្នុងជីវិតរបស់ពួកគេ។

ពួកអ្នកជំនាញមានលទ្ធភាពនៅក្នុងការជួសជុលរូបសំណាកនោះស្ទើរតែទាំងស្រុង ប៉ុន្តែដៃទាំងពីររបស់រូបសំណាកនោះមានការខូចខាតយ៉ាងខ្លាំងរហូតដល់ពួកគេមិនអាចធ្វើឲ្យដូចដើមវិញបាន។ មានមនុស្សមួយចំនួនបានឲ្យយោបល់ថា ពួកគេគួរជួលជាងសូនរូបម្នាក់ឲ្យធ្វើដៃទាំងពីរនោះជាថ្មីឡើងវិញ ប៉ុន្តែមានមនុស្សផ្សេងទៀតចង់ឲ្យវានៅដូចដើម---ទុកជាការចងចាំជារៀងរហូតមួយពីសោកនាដកម្មនៃសង្គ្រាម។ នៅទីបំផុត រូបសំណាកនោះត្រូវរក្សាទុកដោយគ្មានដៃ។ ប៉ុន្តែ ប្រជាជននៅទីក្រុងនោះបានបន្ថែមនូវរបស់មួយ---នៅត្រង់គ្រឹះរបស់រូបសំណាកនោះ គឺពួកគេបានដាក់ស្លាកសញ្ញាមួយដោយមានសរសេរនូវពាក្យដ៏សាមញ្ញថា៖ «ថ្វីបើព្រះគ្រីស្ទគ្មានព្រះហស្តក៏ពិតមែន ប៉ុន្តែយើងមាន»។

យើងគឺជាព្រះហស្តរបស់ព្រះគ្រីស្ទនៅក្នុងដំណើររឿងនេះគឺផ្ទុកនូវមេរៀនដ៏សំខាន់មួយ។ នៅពេលខ្ញុំគិតអំពីព្រះអង្គសង្គ្រោះ ជារឿយៗខ្ញុំនឹកគិតដល់ទ្រង់ជាមួយនឹងព្រហស្តលាតសន្ធឹង ដើម្បីជួយលួងលោមមព្យាបាលប្រទានពរ និងផ្តល់សេចក្តីស្រឡាញ់។ ទ្រង់បានមានបន្ទូលទៅកាន់ ប្រជាជនទូទៅ---ហើយមិនដែលមើលស្រាលចំពោះពួកគេឡើយ។ ទ្រង់ស្រឡាញ់មនុស្សដែលរាបសា និងសុភាព ហើយទ្រង់បានយាងនៅក្នុងចំណោមពួកគេ ដោយបម្រើដល់ពួកគេ និងផ្តល់សេចក្តីសង្ឃឹម និងសេចក្តីសង្គ្រោះ។

នោះគឺជាអ្វីដែលទ្រង់ធ្វើនៅក្នុងជីវិតរមែងស្លាប់របស់ទ្រង់។ វាគឺជាអ្វីដែលទ្រង់នឹងធ្វើ បើទ្រង់មានព្រះជន្មរស់នៅក្នុងចំណោមយើងសព្វថ្ងៃនេះ។ ហើយវាគឺជាអ្វីដែលយើងគួរតែធ្វើនៅក្នុងនាមជាអ្នកដើរតាមទ្រង់ និងក្នុងនាមជាសមាជិកសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ។

នៅពេលព្រឹកដ៏ស្រស់បំព្រងនៃបុណ្យអ៊ីស្ទើរនេះ សូមឲ្យគំនិត និងដួងចិត្តរបស់យើងខិតទៅជិតទ្រង់---ដែលជាសេចក្តីសង្ឃឹមនៃអ៊ីស្រាអែល និងជាពន្លឺនៃពិភពលោក។

នៅពេលយើងធ្វើតាមគំរូដ៏ល្អឥតខ្ចោះរបស់ទ្រង់ នោះដៃរបស់យើងអាចប្រែក្លាយទៅជាព្រះហស្តរបស់ទ្រង់ ភ្នែករបស់យើងក្លាយជាព្រះនេត្ររបស់ទ្រង់ ហើយដួងចិត្តរបស់យើងក្លាយជាព្រះទ័យរបស់ទ្រង់។

ដៃរបស់យើងអាចធ្វើការឱបក្រសោប ខ្ញុំមានចិត្តរំភើបយ៉ាងខ្លាំងតាមរយៈវិធីដែលសមាជិកសាសនាចក្ររបស់យើងបម្រើដល់មនុស្សដទៃទៀត។ នៅពេលយើងឮពីការលះបង់ដោយឥតសំចៃ និងសេចក្ដីមេត្តាដ៏កក់ក្ដៅ នោះដួងចិត្តរបស់យើងពោរពេញដោយអំណរគុណ និងសុភមង្គល។ អ្នកគឺជាពន្លឺដ៏ត្រចះត្រចង់សម្រាប់ពិភពលោកនេះ ហើយអ្នកត្រូវបានគេស្គាល់ដោយសេចក្ដីល្អ និងក្ដីមេត្តារបស់អ្នក។

ជាអកុសល យើងបានឮម្ដងហើយម្ដងទៀតអំពីសមាជិកសាសនាចក្រដែលបានបាក់ទឹកចិត្ត ហើយបន្ទាប់មកក៏ឈប់មកចូលរួមនៅក្នុងការប្រជុំព្រះវិហាររបស់យើង ពីព្រោះពួកគេគិតថាពួកគេគឺជាមនុស្សដែលមិនសក្ដិសម។

កាលពីខ្ញុំនៅក្មេង ប្រទេសអាល្លឺម៉ង់ទទួលរងនូវភាពខ្ទេចខ្ទាំ ដោយសារតែសង្គ្រាមលោកលើកទីពីរ។ មានមនុស្សជាច្រើនទទួលរងនូវភាពស្រេកឃ្លាន មានជម្ងឺ ហើយស្លាប់។ ខ្ញុំនៅចាំយ៉ាងច្បាស់ថា មានការដឹកជញ្ជូនម្ហូបអាហារ និងសំលៀកបំពាក់តាមកប៉ាល់មនុស្សធម៌ជាច្រើនដែលមកពីសាសនាចក្រក្នុងទីក្រុងសលត៍ លេក។ រហូតមកដល់ពេលនេះ ខ្ញុំនៅចាំពីក្លិននៃសំលៀកបំពាក់នោះ ហើយខ្ញុំនៅចាំពីរស់ជាតិដ៏ផ្អែមនៃផ្លែភិចកំប៉ុង។

ប្រហែលជានៅពេលនោះមានមនុស្សមួយចំនួនបានចូលរួមក្នុងសាសនាចក្រដោយសារតែរបស់នេះ។ មានសមាជិកមួយចំនួនបានមើលងាយដល់ពួកអ្នកផ្លាស់ប្រែចិត្តថ្មីទាំងនេះ។ ពួកគេថែមទាំងហៅអ្នកទាំងនោះដោយឈ្មោះមិនសមរម្យថា៖ Büchsen Mormonen ឬ«ពួកអាហារកំប៉ុងមរមន»។ ពួកគេមានការស្អប់ខ្ពើមដល់សមាជិកថ្មីទាំងនេះ ពីព្រោះពួកគេជឿថា នៅពេលសេចក្ដីត្រូវការខាងសាច់ឈាមរបស់អ្នកទាំងនោះត្រូវបានបំពេញ នោះពួកគេនឹងចាកចេញពីសាសនាចក្រ ហើយនិងមិនវិលត្រឡប់មកវិញឡើយ។

ទោះបីជាមានមនុស្សមួយចំនួនបានចាកចេញ ហើយមានភាគច្រើនបន្តនៅក្ដី---ក៏ពួកគេបានភ្លក់នូវភាពផ្អែមល្ហែមនៃដំណឹងល្អ ហើយទទួលអារម្មណ៍នូវការឱបក្រសោបដ៏ទន់ភ្លន់នៃការមើលថែពីសំណាក់បងប្អូនប្រុសស្រីទាំងឡាយដែរ។ ពួកគេបានរកឃើញថា «នគររបស់ព្រះគឺជាផ្ទះរបស់ពួកគេ»។ ហើយឥឡូវនេះ គឺបីទៅបួនជំនាន់ក្រោយមក មានគ្រួសារជាច្រើនបានដេញរកសមាជិកភាពក្នុងសាសនាចក្រត្រឡប់ទៅពួកអ្នកផ្លាស់ប្រែចិត្តទាំងនេះ។

ខ្ញុំសង្ឃឹមថា យើងនឹងស្វាគមន៍ ហើយស្រឡាញ់រាល់កូនចៅរបស់ព្រះ រួមទាំងអស់អ្នកដែលស្លៀកពាក់មានរូបរាង និយាយស្ដី ឬធ្វើអ្វីដែលខុសពីគេផងដែរ។ វាគឺជាអំពើបាបមួយដ៏ធំនៅក្នុងការធ្វើឲ្យមនុស្សដទៃទៀតយល់ថាពួកគេជាមនុស្សដែលគួរឲ្យខ្លាចនោះ។ ចូរយើងជួយលើកស្ទួយមនុស្សដែលនៅជុំវិញយើង។

ចូរយើងលាតសន្ទឹងដៃស្វាគមន៍។ ចូរយើងផ្ដល់ឲ្យបងប្អូនប្រុសស្រីរបស់យើងនៅក្នុងសាសនាចក្រនូវភាពមនុស្សធម៌ ក្ដីមេត្តាករុណា និងសេចក្ដីសប្បុរសដែលធ្វើឲ្យពួកគេទទួលអារម្មណ៍ជារៀងរហូតថា នៅទីបំផុតពួកគេបានស្វែងរកនគរនៃព្រះឃើញហើយ។

នៅពេលយើងត្រូវបានល្បួងឲ្យវិនិច្ឆ័យទៅលើអ្នកណាម្នាក់ ចូរយើងគិតអំពីព្រះអង្គសង្គ្រោះ គឺជាអង្គដែល «ស្រឡាញ់មនុស្សលោកដល់ម្ល៉េះបានជាទ្រង់ប្ដូរជីវិតទ្រង់ផ្ទាល់ដើម្បីទ្រង់អាចទាញមនុស្សទាំងអស់ មករកទ្រង់។ ហេតុដូច្នោះហើយ ទ្រង់មិនដែលបញ្ជាដល់អ្នកណាម្នាក់ថា គេនឹងមិនគួរទទួលយកសេចក្ដីសង្គ្រោះរបស់ទ្រង់នោះឡើយ។

«មើលចុះ តើទ្រង់ដែលបន្លឺសម្លេងដាក់អ្នកណាម្នាក់ថា៖ ថយចេញពីយើងទៅឬអី?...តើទ្រង់ដែលបានបញ្ជាឲ្យអ្នកណាម្នាក់ចេញពីសាលាជំនុំ ឬចេញពីទីកន្លែងថ្វាយបង្គំទាំងឡាយឬទេ? មើលចុះ ខ្ញុំសូមប្រាប់អ្នកថា៖ ទេ។...ប៉ុន្តែទ្រង់មានបន្ទូលថា៖ មករកយើងចុះអស់អ្នករាល់គ្នានៅចុងផែនដីអើយ...[ត្បិត] មនុស្សលោកទាំងអស់ បានទទួលយកឯកសិទ្ធិដូចៗគ្នា ហើយគ្មានអ្នកណាម្នាក់ត្រូវបានហាមប្រាមឡើយ»។11

នៅពេលខ្ញុំបានបទគម្ពីរនេះ វាបានសបញ្ជាក់ថា អស់អ្នកណាដែលទទួលបានការស្ដីបន្ទោសដ៏ខ្លាំងបំផុតរបស់ព្រះអង្គសង្គ្រោះ ជារឿយគឺជាអ្នកដែលលើកខ្លួនឯងឡើងដោយសារតែទ្រព្យសម្បត្តិ ឥទ្ធិពល ឬសេចក្ដីសុចរិតមិនបរិសុទ្ធរបស់ខ្លួន។
មានពេលមួយ ព្រះអង្គសង្គ្រោះបានបង្រៀននូវដំណើររឿងប្រៀបធៀបមួយអំពីបុរសពីរនាក់ដែលចូលទៅក្នុងព្រះវិហារបរិសុទ្ធដើម្បីអធិស្ឋាន។ បុរសទីមួយ គឺជាងពួកផារ៉ាស៊ីដែលមានកិត្តិយសបានអធិស្ឋានថា «ឱព្រះអង្គអើយ ទូលបង្គំអរព្រះគុណដល់ទ្រង់ ព្រោះទូលបង្គំមិនដូចជាមនុស្សឯទៀត ដែលជាមនុស្សប្លន់ទុច្ចរិត ហើយកំផិត ឬដូចជាអ្នកយកពន្ធនេះទេ។ ទូលបង្គំតមក្នុងមួយអាទិត្យពីរដង ហើយក៏ថ្វាយមួយភាគក្នុងដប់ពីរបស់ទាំងអម្បាលម៉ានដែលទូលបង្គំបានចំណេញផង»។

រីឯបុរសម្នាក់ទៀត ជាអ្នកយកពន្ធដែលគេស្អប់ បានឈរ«នៅទីឆ្ងាយមិនទាំងងើបមើលទៅលើមេឃផង ក៏គក់ទ្រូងទូលថា ឱព្រះអង្គអើយ សូមទ្រង់មេត្តាអត់ទោសដល់ទូលបង្គំដែលជាអ្នកមានបាបផង»។ ហើយព្រះយេស៊ូវបានមានបន្ទូលថា «ខ្ញុំប្រាប់អ្នករាល់គ្នាថា កាលចុះទៅដល់ផ្ទះ អ្នកនេះបានរាប់ជាសុចរិតជាជាងអ្នកមួយនោះ»។12

ធាតុពិជាក់ស្ដែង គឺយើង«គ្រប់គ្នាធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ»។13 យើងគ្រប់គ្នាត្រូវការនូវសេចក្ដីមេត្តាករុណា។ នៅថ្ងៃចុងក្រោយ ពេលយើងត្រូវបានហៅទៅកាន់វេទិកាជំនុំជំរះក្ដីរបស់ព្រះ តើយើងមិនសង្ឃឹមថា ភាពមិនល្អឥតខ្ចោះដ៏ច្រើនរបស់យើងនឹងត្រូវបានអភ័យទោសឲ្យទេឬ? តើយើងមិនចង់បាននូវអារម្មណ៍នៃការឱបក្រសោបរបស់ព្រះអង្គសង្គ្រោះទេឬអី?

វាមើលទៅមានតែរឿងម្យ៉ាងប៉ុណ្ណោះដែលត្រឹមត្រូវ ហើយសមរម្យដើម្បីយើងអាចជួយដល់មនុស្សដទៃ គឺជាអ្វីដែលយើងចង់បានយ៉ាងជ្រាលជ្រៅបំផុតសម្រាប់ខ្លួនឯង។

ខ្ញុំពុំមែនមានន័យថា ឲ្យយើងទទួលយកអំពើបាប ឬអំពើអាក្រក់នោះទេ។ ទោះជាយ៉ាងក្តី នៅក្នុងសេចក្តីក្លាហានរបស់យើង ពេលខ្លះយើងមានការភ័ន្តច្រឡំរវាងអំពើបាប និងអ្នកមានបាប ហើយយើងធ្វើការថ្កោលទោសយ៉ាងឆាប់រហ័ស និងខ្វះនូវសេចក្តីមេត្តាករុណា។ យើងបានរៀនពីវិវរណៈសម័យទំនើបថា «តម្លៃនៃព្រលឹងទាំងឡាយគឺមហិមាណាស់ចំពោះព្រះនេត្រនៃព្រះ»។ 4 យើងមិនអាចកំណត់តម្លៃនៃដួងព្រលឹងមួយទៀតឲ្យលើសពីអ្វីដែលយើងអាចវាស់នូវប្រវែងនៃសាកលលោកនេះបានឡើយ។ មនុស្សគ្រប់រូបដែលយើងបានជួបគឺជាមនុស្សដ៏សំខាន់ចំពោះព្រះវរបិតាសួគ៌យើង។ នៅពេលយើងយល់ពីការណ៍នេះ នោះយើងអាចចាប់ផ្តើមយល់ពីរបៀបដែលយើងគួរប្រព្រឹត្តចំពោះមនុស្សដទៃ។

មានស្ត្រីម្នាក់ដែលបានឆ្លងកាត់ការសាកល្បង និងទុក្ខសោកជាច្រើនឆ្នាំបាននិយាយទាំងទឹកភ្នែកថា «ខ្ញុំបានដឹងថា ខ្ញុំប្រៀបដូចជាក្រដាសប្រាក់ 20 ដុល្លារមួយដ៏ចាស់ ---ដែលត្រូវបានគេឈ្លី ហែក មានភាពកខ្វក់ ត្រូវគេបំភ័ន្ត  និងធ្វើឲ្យខូចខាតដូច្នោះដែរ។ ប៉ុន្តែ ខ្ញុំនៅតែជាក្រដាសប្រាក់ 20 ដុល្លារដដែល។ ខ្ញុំនៅមានតម្លៃ។ ទោះបីជាខ្ញុំ អាចមានរូបរាងមិនដូចដើម ហើយទោះបីជាខ្ញុំត្រូវខ្ទុកខ្ទី និងត្រូវបានគេប្រើក្តី ក៏ខ្ញុំនៅមានតម្លៃ 20 ដុល្លារពេញដែរ»។
ដៃរបស់យើងអាចធ្វើការលួងលោមចិត្ត ចូរឲ្យដួងចិត្ត និងដៃទាំងទ្វេររបស់យើងបានលាតសន្ធឹងចេញទៅក្នុងក្តីមេត្តាករុណាចំពោះអ្នកដទៃ ពីព្រោះមនុស្សគ្រប់រូបកំពុងដើរនៅលើផ្លូវដ៏លំបាករបស់ខ្លួន។ ក្នុងនាមជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ យើងត្រូវបានហៅឲ្យគាំទ្រ និងព្យាបាលជាជាងការថ្កោលទោស។ យើងត្រូវបានបញ្ជាឲ្យទួញយំជាមួយនិងអស់អ្នកណាដែលទួញយំ ហើយកំសាន្តចិត្តដល់អស់អ្នកណាដែលត្រូវការកំសាន្តចិត្ត។ 5

ចំពោះការគិតថា អស់អ្នកដែលរងទុក្ខគួរសក្តិសមនឹងទទួលបានការណ៍នោះហើយ គឺពុំមែនជាការត្រឹមត្រូវឡើយក្នុងនាមយើងជាគ្រីស្ទាន។ ថ្ងៃអាទិត្យនៃបុណ្យអ៊ីស្ទើរ គឺជាថ្ងៃដ៏ល្អមួយដើម្បីនឹកចាំថា ព្រះអង្គសង្គ្រោះរបស់យើងបានយល់ព្រមលើកដាក់មកលើអង្គទ្រង់នូវការឈឺចាប់ ជម្ងឺ និងការរងទុក្ខរបស់យើងរាល់គ្នា---រួមទាំងយើងទាំងអស់គ្នាដែលមើលទៅគួរតែទទួលការរងទុក្ខនោះក្តី។ 6

នៅក្នុងព្រះគម្ពីរសុភាសិតបានចែងថា «មិត្តសំឡាញ់រមែងស្រឡាញ់គ្នានៅគ្រប់វេលា ឯបងប្អូនក៏កើតមកសម្រាប់គ្រាលំបាកដែរ»។ 7 ចូរយើងមានសេចក្តីស្រឡាញ់គ្រប់ពេលទាំងអស់។ ហើយជាពិសេស ចូរយើងជួយដល់បងប្អូនប្រុសស្រីរបស់យើងក្នុងគ្រានៃសេចក្តីរងទុក្ខវេទនា។

ដៃរបស់យើងអាចធ្វើការបម្រើ រឿងនិទានបុរាណមួយរបស់សាសន៍យូដាបានដំណាលពីបងប្អូនប្រុសពីរនាក់ ឈ្មោះ អ័ប្រាំ និងហ្សិមរី ដែលជាម្ចាស់លើស្រែមួយកន្លែង ហើយពួកគេធ្វើស្រែនោះជាមួយគ្នា។ ពួកគេបានយល់ធ្វើការពាក់កណ្តាលម្នាក់ ហើយចែកផលស្មើគ្នា។ មានយប់មួយ លុះការច្រូតកាត់យកផលបានជិតចូលមកដល់ ហ្សិមរី ក៏ដេកមិនលក់ ពីព្រោះវាដូចជាមិនយុត្តិ ធម៌សោះចំពោះអ័ប្រាំ ដែលត្រូវចិញ្ចឹមបីបាច់ដល់ប្រពន្ធ និងកូនប្រុសប្រាំពីរនាក់ ហើយបែរជាទទួលបានផលតែពាក់កណ្តាលដូចជាខ្លួនដែលជាមនុស្សនៅលីវដែរ។

ដូច្នេះ ហ្សិមរី ក៏បានស្លៀកពាក់ ហើយចេញទៅវាលស្រែដោយស្ងាត់ៗ ហើយគាត់ក៏បានយកមួយភាគបីនៃផលរបស់ខ្លួនទៅដាក់នៅក្នុងពំនូករបស់បងប្អូនប្រុសគាត់។ បន្ទាប់មក គាត់ក៏ត្រឡប់មកសំរាកវិញដោយគិតថាគាត់បានធ្វើនូវរឿងដ៏ត្រឹមត្រូវមួយ។

ក្នុងពេលតែមួយ អ័ប្រាំ ក៏ដេកមិនលក់ដែរ។ គាត់បានគិតដល់បងប្អូនប្រុសគាត់ ហ្សិមរី ដែលរស់នៅតែម្នាក់ឯង ហើយគ្មានកូនប្រុសជួយគាត់ធ្វើការងារច្រូតកាត់។ វាដូចជាមិនយុត្តិធម៌សោះដែលហ្សិមរី ជាអ្នកដែលខិតខំធ្វើការ ត្រូវទទួលបានតែចំណែកពាក់កណ្តាលនៃការច្រូតកាត់នោះ។ ពិតណាស់ ការណ៍នេះនឹងមិនធ្វើព្រះសព្វព្រះទ័យឡើយ។ ហេតុដូច្នេះហើយ អ័ប្រាំបានចេញទៅវាលស្រែដោយស្ងៀមស្ងាត់ ហើយយកបីភាគនៃផលរបស់គាត់ទៅដាក់នៅក្នុងពំនូកនៃផលរបស់ប្អូនប្រុសជាទីស្រឡាញ់របស់គាត់។

លុះស្អែកឡើង បងប្អូនប្រុសទាំងពីរបានចេញទៅវាលស្រែ ហើយពួកគេក៏មានការភ្ញាក់ផ្អើល ដោយសារពំនូករបស់ពួកគេទាំងពីរនៅដដែល។ លុះយប់ឡើង បងប្រុសទាំងពីរនាក់នោះបានចេញពីផ្ទះរបស់ខ្លួនទៅធ្វើកិច្ចការដដែលដូចជាយប់ម្សិលដែរ។ ប៉ុន្តែ លើកនេះពួកគេបានជួបគ្នា ហើយនៅពេលដែលពួកគេបានឃើញដូច្នេះ នោះពួកគេបានសម្រក់ទឹកភ្នែក ហើយឱបគ្នាទៅវិញទៅមក។ ពួកគេគឺគ្មានពាក្យនឹងថ្លែងឡើយ ត្បិតដួងចិត្តរបស់ពួកគេគឺពោរពេញដោយសេចក្តីស្រឡាញ់ និងការដឹងគុណ។8

នេះគឺជាវិញ្ញាណនៃក្តីមេត្តាករុណា៖ ដែលយើងស្រឡាញ់អ្នកដទៃដូចជាខ្លួនឯង 9 ស្វែងរកសុភមង្គលរបស់ពួកគេ ហើយប្រព្រឹត្តចំពោះពួកគេដូចជាយើងប្រព្រឹត្តចំពោះខ្លួនឯងដែរ។ 10

សេចក្តីស្រឡាញ់ពិតត្រូវមានការអនុវត្តន៍។ យើងអាចនិយាយអំពីសេចក្តីស្រឡាញ់ពេញមួយថ្ងៃ---យើងអាចសរសេរលិខិតខ្លីៗ ឬកំណាព្យដែលលើកឡើងពីសេចក្តីស្រឡាញ់ ច្រៀងចម្រៀងដែលសរសើរដំកើងពីសេចក្តីស្រឡាញ់ និងផ្សាយការទេសនាដែលលើកទឹកចិត្តឲ្យមានសេចក្តីស្រឡាញ់ក៏ពិតមែន---ប៉ុន្តែពាក្យសម្តីរបស់យើងនឹងក្លាយជាអាសារឥតការ ដែលប្រៀបបានទៅនឹង «លង្ហិនដែលឮខ្ទរ ឬដូចជាឈឹងដែលឮទ្រហឹងប៉ុណ្ណោះ» លុះត្រាយើងបង្ហាញសេចក្តីស្រឡាញ់នោះឲ្យកើតជាសកម្មភាពផងដែរ។ 11

ព្រះគ្រីស្ទមិនគ្រាន់តែមានបន្ទូលដោយក្តីស្រឡាញ់ប៉ុណ្ណោះទេ តែទ្រង់ក៏បានបង្ហាវាជារៀងរាល់ថ្ងៃក្នុងដំណើរជីវិតរបស់ទ្រង់ផងដែរ។ ទ្រង់មិនបានញែកអង្គទ្រង់ចេញពីហ្វូងមនុស្សឡើយ។ ការស្ថិតនៅក្នុងចំណោមមនុស្ស ទ្រង់បានជួលដល់មនុស្សម្នាក់ម្តងៗ។ ទ្រង់បានជួយសង្គ្រោះដល់មនុស្សដែលវង្វេងផ្លូវ។ ទ្រង់មិនមែនគ្រាន់បង្រៀននៅក្នុងថ្នាក់មួយអំពីការជួយដោយក្តីស្រឡាញ់ រួចហើយប្រគល់ការងារជាក់ស្តែងទៅឲ្យអ្នកដទៃនោះទេ។ ទ្រង់មិនមែនបង្រៀនត្រឹមតែម្យ៉ាងនោះទេ ប៉ុន្តែទ្រង់ក៏បានបង្ហាញយើងពីរបៀបដើម្បី «ជួយអ្នកទន់ខ្សោយ លើកដៃដែលពោយ ហើយចម្រើនកម្លាំងដល់ក្បាលជង្គង់ដែលញ័រ» ផងដែរ។ 12

ព្រះគ្រីស្ទជ្រាបពីរបៀបដ៏ល្អឥតខ្ចោះដើម្បីបម្រើដល់មនុស្សដទៃ។ នៅពេលព្រះអង្គសង្គ្រោះលាតសន្ធឹងព្រះហស្តរបស់ទ្រង់ នោះអស់អ្នកដែលទ្រង់បានប៉ះត្រូវបានលើកដំកើង ហើយប្រែក្លាយជាមនុស្សដ៏ប្រពៃនិងមានភាពរឹងមាំ។

បើយើងគឺជាព្រះហស្តរបស់ទ្រង់ តើយើងនឹងមិនធ្វើកិច្ចការដូចគ្នានេះទេឬអី?

ដៃរបស់យើងគឺជាព្រះហស្តរបស់ទ្រង់ ព្រះអង្គសង្គ្រោះបានបើកសម្តែងនូវអាទិភាពដ៏ល្អឥតខ្ចោះសម្រាប់ជីវិតរបស់យើង គេហដ្ឋាន វួដ និងសហគមន៍របស់យើង នៅពេលទ្រង់មានបន្ទូលអំពីព្រះបញ្ញត្តិដ៏ធំថា៖ «ត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ជាព្រះនៃឯងឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង ហើយអស់អំពីគំនិតឯង»។13 នៅពេលព្រះបញ្ញត្តិដ៏ធំទាំងពីរនេះក្លាយជាកត្តាដ៏សំខាន់ក្នុងជីវិតរបស់យើង នោះអ្វីៗគ្រប់យ៉ាងនឹងមានភាពត្រឹមត្រូវ ពីព្រោះ «បណ្តាក្រិត្យវិន័យ និងអស់ទាំងទំនាយហោរាទាំងប៉ុន្មាន ក៏សម្រេចនៅបទបញ្ញត្តិទាំងពីរប្រការនេះឯង»។14

យើងមានជម្រើសមួយនៅក្នុងរបៀបដែលចំណាយពេលវេលារបស់យើងនៅលើផែនដីនេះ។ យើងអាចចំណាយពេលវេលារបស់យើងគិតពិចារណាពីរឿងលំអិតនៃជីវិត និងក្រិត្យវិន័យ។ ប៉ុន្តែ បើយើងមិនគិតដល់ព្រះបញ្ញត្តិដ៏ធំនោះ នោះអ្វីៗទាំងអស់នឹងក្លាយជាអាសារឥតការ ហើយយើងនឹងក្លាយទៅជាពពកឥតទឹកដែលត្រូវខ្យលបក់ផាត់ទៅមក និងជាដើមឈើឥតផ្លែ។15

តើយើងមិនស្រឡាញ់ព្រះជាព្រះវរបិតា និងបងប្អូនរបស់យើងទេឬអី ពីព្រោះការណ៍នោះគឺជាកត្តាដ៏សំខាន់នៅក្នុងការដើរតាមព្រះយេស៊ូវ ដែលជាព្រះគ្រីស្ទ? សេចក្តីសប្បុរសធម៌ គឺជាឥរិយាបទដែលសិស្សរបស់ទ្រង់ និងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទត្រូវបានគេទទួលស្គាល់នៅជុំវិញពិភពលោក។ 16 បើគ្មានសេចក្តីស្រឡាញ់ នោះយើងគ្រាន់តែជាទ្រង់ទ្រាយមួយនៃសិស្ស និងសាសនាចក្ររបស់ទ្រង់---ដែលគ្មានខ្លឹមសារអ្វីទាំងអស់។

តើការបង្រៀនរបស់យើងដោយគ្មាននូវសេចក្តីស្រឡាញ់នោះ វាមានលក្ខណៈល្អបែបណាដែរ? តើកិច្ចការផ្សព្វផ្សាយសាសនា កិច្ចការព្រះវិហារបរិសុទ្ធ ឬកិច្ចការសុខុមាលភាពមានលក្ខណៈល្អបែបណាដែរ បើគ្មានសេចក្តីស្រឡាញ់នោះ? សេចក្តីស្រឡាញ់ គឺជាអ្វីមួយដែលបានបំផុសគំនិតដល់ព្រះវរបិតាសួគ៌ឲ្យបង្កើតវិញ្ញាណរបស់យើងឡើង។ វាគឺជាអ្វីមួយដែលបានដឹកនាំព្រះអង្គសង្គ្រោះទៅកាន់សួនច្បារគែតសេម៉ានី ដើម្បីលះបង់រូបកាយរបស់ទ្រង់សម្រាប់អំពើបាបរបស់យើង។ សេចក្តីស្រឡាញ់ដ៏សុទ្ធសាធនៃព្រះគ្រីស្ទ គឺជាកត្តាដ៏សំខាន់នៅក្នុងផែនការសង្គ្រោះ។ វាគឺជាប្រភពនៃសុភមង្គល ជាការព្យាបាលថ្មីមួយដែលពុំធ្លាប់មាន និងជាគ្រឹះដ៏មានតម្លៃនៃសេចក្តីសង្ឃឹម។

នៅពេលយើងលាតសន្ធឹងដៃរបស់យើងទៅរកមនុស្សដទៃទៀតនៅក្នុងសេចក្តីស្រឡាញ់ដូចជាព្រះគ្រីស្ទនោះនឹងមានអ្វីមួយដែលអស្ចារ្យកើតឡើងចំពោះយើង។ វិញ្ញាណរបស់យើងនឹងត្រូវបានព្យាបាល ហើយនឹងត្រូវបានលាងសំអាត និងកាន់តែមានភាពរឹងមាំ។ យើងនឹងរីករាយ មានសេចក្តីសុខសាន្ត និងស្តាប់ការខ្សឹបប្រាប់ពីព្រះវិញ្ញាណបរិសុទ្ធកាន់តែច្រើនឡើង។

បងប្អូនប្រុសស្រី និងមិត្តភក្តិជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំសូមបន្លឺសម្លេងរបស់ខ្ញុំឡើងថ្លែងអំណរគុណដល់ព្រះវរបិតាសួគ៌របស់យើង សម្រាប់អំណោយទាននៃព្រះរាជបុត្រារបស់ទ្រង់។ ខ្ញុំសូមថ្លែងអំណរគុណដោយអស់ពីដួងចិត្ត និងព្រលឹងរបស់ខ្ញុំសម្រាប់ជីវិត និងគំរូរបស់ព្រះយេស៊ូវគ្រីស្ទ និងសម្រាប់ការលះបង់ដែលគ្មាននូវអំពើបាប និងភាពអាត្មានិយមរបស់ទ្រង់។ ខ្ញុំមានក្តីរីករាយដោយបានដឹងថា ទ្រង់មិនបានសុគតឡើយ ប៉ុន្តែទ្រង់បានមានព្រះជន្មរស់ឡើងវិញ! ទ្រង់រស់ ហើយបានត្រឡប់មកកាន់ផែនដីដើម្បីស្តារឡើងវិញនូវសិទ្ធិអំណាច និងដំណឹងល្អរបស់ទ្រង់ដល់មនុស្សលោក។ ទ្រង់បានប្រទានឲ្យយើងនូវគំរូដ៏ល្អឥតខ្ចោះអំពីប្រភេទនៃមនុស្សដែលយើងគួរប្រែក្លាយ។

នៅថ្ងៃអាទិត្យនៃបុណ្យអ៊ីស្ទើរនេះ និងជារៀងរាល់ថ្ងៃ នៅពេលយើងសញ្ជឹងគិតដោយមានគារវភាព និងដោយស្ញើចសរសើរអំពីរបៀបដែលព្រះអង្គសង្គ្រោះឱបក្រសោបយើង លួងលោមយើង និងព្យាបាលយើង ចូរយើងប្តេជ្ញាចិត្តដើម្បីធ្វើជាព្រះហស្តរបស់ទ្រង់ ដើម្បីធ្វើឲ្យមនុស្សដទៃទៀតទទួលអារម្មណ៍នូវការឱបក្រសោបប្រកបដោយក្តីស្រឡាញ់របស់ទ្រង់តាមរយៈយើង។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. នីហ្វៃទី 2 26:24--28 ។ ការគូសបញ្ជាក់ត្រូវបានបន្ថែម។
2. លូកា 18:9--14។
3. រ៉ូម 3:23។
4. គ. និង ស. 18:10។
5. សូមមើល ម៉ូសាយ 18:9។

6. សូមមើល អាលម៉ា 7:11--13 គោលលទ្ធិ និង សេចក្ដីសញ្ញា 19:16។
7. សុភាសិត 17:17។
8. សូមមើល Clarence Cook «Abram and Zimri» Poems (ឆ្នាំ 1902) ទំព័រ 6--9។
9. សូមមើល ម៉ាថាយ 22:39។
10. សូមមើល ម៉ាថាយ 7:12។
11. កូរិនថូសទី 1 13:1។
12. គោលលទ្ធិ និង សេចក្ដីសញ្ញា 81:5។
13. ម៉ាថាយ 22:37--39។
14. ម៉ាថាយ 22:40។
15. សូមមើល យូដាស 1: 12។
16. សូមមើល យ៉ូហាន 13:35។